# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

********

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌសើរើ

លេខ : ០១ សរ.

ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

សាលដីកា

លេខ : ២៤

ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០០១

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះរួមក្រុម ជាសាធារណៈ នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ឃឹម** | **ប៉ុណ្ណ** | ជាប្រធាន |
| ២- | លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៣- | លោក | ប៉ែន | ស៊ុន | ជាចៅក្រម |
| ៤- | លោក | វៀល | មួន | ជាចៅក្រម |
| ៥- | លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៦- | លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៧- | លោក | ជីវ | កេង | ជាចៅក្រម |
| ៨- | លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៩ | លោក | **ឃឹម** | **សុខឡឹន** | ជាចៅក្រម **រង្វាយការណ៍** |

ក្រឡាបញ្ជី

លោក វ៉ាន់ បូរ៉ាត

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសើរើ ពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី ១២-៧-២០០០ របស់តុលាការកំពូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ០៤ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ ។

ពីបទ : ក្លែងបន្លំហត្ថលេខា លើកិច្ចសន្យា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៣-១១-៩៤ តាមបញ្ញត្តិមាត្រា ៤៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ទណ្ឌិតឈ្មោះ ទូ សុវណ្ណារ៉ា ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជីអិដ្ឋ ស្រុក

កៀនស្វាយ ខេត្តកណ្ដាល របររកស៊ី នាយកសាលាចំណេះទូទៅឯកជនសំពៅមាស មានទីលំនៅផ្ទះលេខ១០ ក្រុម ៥២ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ នួ សាម៉េត ( រស់ ) ម្ដាយឈ្មោះ អ៊ុច ចាន់ថៃ ( រស់ ) ប្រពន្ធឈ្មោះ ស ភិនសុគន្ធី មានកូន ០៤នាក់ ។

- ឈ្មោះ ស ភិនសុគន្ធី ជាប្រពន្ធទណ្ឌិត ( ជាម្ចាស់បណ្ដឹងសើរើ )

មានមេធាវី លោក ហែម វុន ការពារឱ្យម្ចាស់បណ្ដឹងសើរើ

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ នេត វណ្ណៈ ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅ ផ្ទះលេខ ១៣៨Eo ផ្លូវលេខ ៦៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

គ្មានមេធាវី

តាម បណ្ដឹងសើរើ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ របស់អ្នកស្រី សរ ភិនសុគន្ធី ជាប្រពន្ធទណ្ឌិតឈ្មោះ នួ សុវណ្ណារ៉ា ដែលប្ដឹងសើរើ ពីសាលដីកាព្រហ្មទណ្ឌ លេខ ៣២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០ របស់តុលាការកំពូល ដោយជូនជាភស្តុតាងថ្មី នៃ លទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់អគ្គនាយកដ្ឋាននគរបាលជាតិ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ការិយាល័យកោសល្យវិច្ច័យទូទៅ នៃ ក្រសួងមហាផ្ទៃ ។

តាមពាក្យបណ្ដឹងសើរើ ចុះថ្ងៃទី ២២-០១-២០០១ របស់ឈ្មោះ ស ភិនសុគន្ធី (ជាប្រពន្ធរបស់ទណ្ឌិត ) បានអះអាងថា នាងខ្ញុំកើតទុក្ខពុំសុខចិត្ត និង ការសំរេចសេចក្ដីរបស់តុលាការកន្លងមក ដោយសំរេចដាក់ពន្ធនាគារប្ដីរបស់នាងខ្ញុំចំនួន ០៥ឆ្នាំ ហើយ ពិន័យជាប្រាក់ចំនួន ៨.០០០.០០០រៀល ( ប្រាំបីលានរៀល ) និង សំណងជម្ងឺចិត្តចំនួន ៣.០០០$ ( បីពាន់ដុល្លាអាមេរិក ) ហើយចោទប្រកាន់ប្ដីនាងខ្ញុំ ថាបានក្លែងបន្លំហត្ថលេខា លើកិច្ចសន្យា ។ កាលសំរេចសេចក្ដីកន្លងមកនេះ គ្រាន់តែសំអាងលើការធ្វើកោសល្យវិច្ច័យ រវាងកិច្ចសន្យា តែពីរប៉ុណ្ណោះ គឺកិច្ចសន្យា ចុះថ្ងៃទី ៣០-៧-៩៤ ដែលចុះហត្ថលេខា រវាងឈ្មោះ ស៊ុន គីមសុង , គង់ សុផល , វ៉ុត ដារុទ្ធ និង ឈ្មោះ នេត វណ្ណៈ ជាមួយ និង កិច្ចសន្យា ចុះថ្ងៃទី ០៥-៨-៩៤ ដែលចុះហត្ថលេខារវាងឈ្មោះ ស៊ុន គីមសុង ជាមួយឈ្មោះ នួ សុវណ្ណារ៉ា ។

នាងខ្ញុំសូមអនុញ្ញាត្ត លើកយកចំនុចសំខាន់ៗ ចំនួន ៤ចំនុច ដែលអាចបញ្ជាក់បានថា ប្ដីរបស់នាងខ្ញុំ ពុំមានពិរុទ្ធភាព ពីបទក្លែងហត្ថលេខាឡើយ :

ចំណុចទី១ : តុលាការក្រុងភ្នំពេញ បានធ្វើកោសល្យវិច្ច័យលើកិច្ចសន្យា ចុះថ្ងៃទី ៣០-៧-៩៤ ដែលចុះហត្ថលេខា ដោយឈ្មោះ ស៊ុន គីមសុង , គង់ សុផល , វ៉ុត ដារុទ្ធ និង នេត វណ្ណ : ជាមួយកិច្ចសន្យា ចុះថ្ងៃទី ០៥-៨-៩៤ ដែលចុះហត្ថលេខារវាង ស៊ុន គីមសុង និង នួ សុវណ្ណារ៉ា ថាតើហត្ថលេខារបស់ ស៊ុន គីមសុង តែមួយ ឬ ក៏មិនមែន ។ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានចេញតារាងផ្សព្វផ្សាយលទ្ធផល ប្រៀបធៀបលេខ ០១៩ ចុះថ្ងៃទី ០៩-១០-៩៥ ដោយប្រកាសថា " មិនមែនជាស្នាមហត្ថលេខារបស់មនុស្សតែម្នាក់ " ។

នាងខ្ញុំសូមលើកយក ដីកាចាត់តាំងអ្នកជំនាញមួយទៀត ដែលចុះហត្ថលេខាដោយលោក

ប្រធានតុលាការក្រុងភ្នំពេញ តែមួយ គឺលេខ ៣០៧៨ តព្រ. ចុះថ្ងៃទី ២១-៧-៩៥ ដោយចាត់តាំងលោក ប្រធានការិយាល័យបច្ចេកទេស នៃ ស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ ពិនិត្យ វាយតម្លៃ និង សន្និដ្ឋាន នូវ ចំនុច គឺ ហត្ថលេខារបស់ឈ្មោះ នេត វណ្ណៈ, វ៉ុត ដារ៉ុទ្ធ, គង់ សុផល និង ស៊ិន គឹមសុង ក្នុងកិច្ចសន្យា ចុះថ្ងៃទី ៣០-៧-៩៤ ខាងលើដូចគ្នា នឹង ហត្ថលេខាឈ្មោះ នេត វណ្ណៈ, វ៉ុត ដារ៉ុទ្ធ, គង់ សុផល និង ស៊ិន គឹមសុង ក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ ដែរឬទេ ? ប៉ុន្តែគួរឱ្យសោកស្តាយជាទីបំផុត ដោយខាងការិយាល័យបច្ចេកទេស ពុំបានធ្វើកោសល្យវិច្ច័យ លើកិច្ចសន្យាខាងលើ ផ្ញើមកឱ្យតុលាការក្រុង ឡើយ ។ ដែលជាហេតុធ្វើឱ្យតុលាការខ្វះកោសល្យវិច្ច័យ សំរាប់យកមកធ្វើការប្រៀបធៀបថា តើហត្ថលេខា របស់ ស៊ិន គឹមសុង ក្នុងកិច្ចសន្យាចុះថ្ងៃទី ៣០-៧-៩៤ វាដូចគ្នាក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ ដែរឬទេ? ។ ហេតុនេះហើយ នាងខ្ញុំយល់ថា បើការិយាល័យបច្ចេកទេសបានធ្វើកោសល្យវិច្ច័យលើកិច្ចសន្យា ខាងលើជាមួយប័ណ្ណប្រគល់ប្រាក់នោះនឹងសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ឈ្មោះស៊ិន គឹមសុង ចុះហត្ថលេខា ចំនួន បីលើក គឺខុសគ្នាទាំងបីលើក បានន័យថា ហត្ថលេខារបស់ ស៊ិន គឹមសុង ដែលលោក នេត វណ្ណៈ ទទួលស្គាល់ នៅក្នុងកិច្ចសន្យាជួលសណ្ឋាគារ វង្គសាល ភោជនីយដ្ឋាន ឈ្មោះសណ្ឋាគារច័ន្ទរះ ចុះថ្ងៃទី ៣០-៧-៩៤ និង ហត្ថលេខារបស់ ស៊ិន គឹមសុង នៅក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ នោះ ក៏ពុំដូចគ្នា ដែរ ( យោងតាមតារាងប្រកាសលទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ២៧-០២-២០០១ របស់នាយកដ្ឋាន នគរបាលបច្ចេកទេស វិទ្យាសាស្ត្រ ក្រសួងមហាផ្ទៃ ) ។

សរុបសេចក្តីមក ហត្ថលេខារបស់ឈ្មោះ ស៊ិន គឹមសុង នៅក្នុងកិច្ចសន្យាជួលសណ្ឋាគារ ចុះថ្ងៃទី ៣០-៧-៩៤ នៅក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ និង នៅក្នុងកិច្ចសន្យាអាជីវកម្មទ្វេរ ភាគីរវាង ស៊ិន គឹមសុង និង នូ សុវណ្ណារ៉ា ចុះថ្ងៃទី ០៥-៨-៩៤ គឺប្រាកដជាហត្ថលេខារបស់ ឈ្មោះ ស៊ិន គឹមសុង តែម្នាក់ឯងគត់ ដោយគ្មាននរណាម្នាក់មកក្លែងបន្លំហត្ថលេខានោះឡើយ ។ ដូច្នេះលោក នូ សុវណ្ណារ៉ា ពុំបានក្លែងហត្ថលេខារបស់ឈ្មោះ ស៊ិន គឹមសុង នៅក្នុងកិច្ចសន្យាអាជីវកម្មទ្វេរភាគី ចុះថ្ងៃ ទី ០៥-៨-៩៤ ដូចដែលតុលាការ ធ្វើការចោទប្រកាន់កន្លងមកនោះទេ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញ ថា : សំរេច ចោទប្រកាន់លើឈ្មោះនូ សុវណ្ណារ៉ា ពីបទៈ ក្លែងលិខិតពាណិជ្ជកម្ម ក្នុងគោលបំណងឆបោកទ្រព្យសម្បត្តិអ្នក ដទៃ កាលពីថ្ងៃទី ០៥-៨-៩៤ តាមមាត្រា ៥០, ៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ១៤ " ខ " ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១- ផ្តន្ទាទោសឈ្មោះ នូ សុវណ្ណារ៉ា ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ គិតពីថ្ងៃ ឃុំខ្លួន ពិន័យជា ប្រាក់ចំនួន ៨លានរៀល និង សងជម្ងឺចិត្តចំនួន ៣ពាន់ដុល្លាអាមេរិក ទៅឈ្មោះ ស៊ិន គឹមហុង ពីបទក្លែង លិខិតឯកជន និង ឆបោក សំណូមពរលើសពីនេះ បដិសេធចោល ។

២- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជន

ជាប់ចោទ បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងទាស់លេខ ១៦ " ខ " ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៦ របស់ឈ្មោះ នូ សុវណ្ណារ៉ា ដែលប្តឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤ " ខ " ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌ ៤៧ " ខ " ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១- តម្កល់សាលក្រមលេខ ១៤ " ខ " ចុះថ្ងៃទី ២៣-០៤-៩៦ ទុកជាបានការពេញទាំងមូល បើមិនព្រមសង បង្គាប់ដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

២- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៥ " ខ " ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៦ របស់ឈ្មោះ នូ សុវណ្ណារ៉ា ដែលប្តឹងសាលក្រមព្រហ្មទណ្ឌលេខ៤៧ " ខ " ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា :

១- ទទួលបណ្តឹងឧទ្ធរណ៍ របស់ជនជាប់ចោទឈ្មោះ នូ សុវណ្ណារ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែជិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤ " ខ " ចុះថ្ងៃទី ២៣-៤-៩៦ និង សាលក្រមលេខ ៤៧ " ខ " ចុះថ្ងៃទី ១០-៩-៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល តែត្រូវបន្ថែមបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ តាមមាត្រា៥២ និង សំរេចប្រាក់ពិន័យឱ្យដាច់ដោយឡែកពីប្រាក់ជម្ងឺចិត្ត ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ១៣៧ ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៦ របស់ជនជាប់ចោទឈ្មោះ នូ សុវណ្ណារ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ នឹង គតិច្បាប់ ។

២- តំកល់សាលក្រមព្រហ្មទណ្ឌលេខ ៤៧ " ខ " ចុះថ្ងៃទី ១០-៩-៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខគូក្តី បើកផ្លូវប្តឹងទាស់ និង សាទុក្ខ ក្នុងកំណត់ច្បាប់ ។

៤- សាលដីកានេះ ជំនុំជំរះ ចំពោះមុខជនជាប់ចោទទាំង ៤នាក់ ចំពោះមេធាវីការពារជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី ការពារជនជាប់ចោទទាំង ៤ និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវសាទុក្ខក្នុង

កំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងទាស់លេខ ៣២ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់ឈ្មោះ សោម ច័ន្ទឌីណា មេធាវីការពារជនជាប់ចោទ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៣៧ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌ ១៣៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់លោកមេធាវី សោម-ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២- ទទួលពាក្យសុំពន្យាពេលសវនាការ ចុះថ្ងៃទី ២៣-៧-៩៧ និង ការសុំពន្យាពេលសវនាការរបស់លោក មេធាវី សោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣- តម្កល់សាលដីកាព្រហ្មទណ្ឌ កំបាំងមុខលេខ ១៣៧ ចុះថ្ងៃទី ២៧-៦-៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់លោក សោម ច័ន្ទឌីណា មេធាវីការពារជនជាប់ចោទ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាង មហាអយ្យការ អម តុលាការកំពូល ថា :

១- បណ្ដឹងសាទុក្ខរបស់លោក សោម ចន្ទ័ឌីណា ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

២- តម្កល់សាលដីកា ព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២-៦-៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០ របស់តុលាការកំពូល ដែលបានសំរេច :

១- ទទួលបណ្ដឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ០៤-៦-៩៩ របស់លោក សោម ច័ន្ទឌីណា មេធាវីការពារឱ្យជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២-៦-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០០០ ។

- បានឃើញ បណ្ដឹងសើរើលេខ ០១ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ របស់អ្នកស្រី សភិន សុគន្ធី ជាប្រពន្ធរបស់ទណ្ឌិតឈ្មោះ នូ សុវណ្ណារ៉ា ដែលប្ដឹងមិនសុខចិត្ត ពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០ ។

- បានឃើញ សារណា ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ឈ្មោះ នូ សុវណ្ណារ៉ា " ម្ចាស់បណ្ដឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញ សារណាតប ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០០ របស់ឈ្មោះ នេត វណ្ណៈ " ចុងបណ្ដឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា : ពុំមានភស្ដុតាងច្បាស់លាស់ អាចឱ្យបដិសេធសាលដីកាព្រហ្មទណ្ឌលេខ៣២ ចុះថ្ងៃទី១២-៧-២០០០ របស់តុលាការកំពូល បានឡើយ ។ ទុកជាមោឃៈនូវបណ្ដឹងសើរើ ចុះថ្ងៃទី ២២-០១-២០០១ របស់នាង សភិន សុគន្ធី ។

- បានស្ដាប់ចម្លើយអះអាងរបស់អ្នកស្រី សភិន សុគន្ធី " ជាម្ចាស់បណ្ដឹងសើរើ " នាពេលជំនុំជំរះថា: សូមគោរពក្រុមប្រឹក្សាជំនុំជំរះ ភស្ដុតាងថ្មី ដែលនាងខ្ញុំលើកយកមកជាសំអាង សំរាប់បណ្ដឹងសើរើនេះ គឺលទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ២៧-០២-២០០១ របស់នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រក្រសួងមហាផ្ទៃ លើហត្ថលេខារបស់ឈ្មោះ ស៊ុន គីមសុង នៅក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ ជាមួយហត្ថលេខារបស់ឈ្មោះ ស៊ុន គីមសុង នៅក្នុងកិច្ចសន្យាជួលសណ្ឋាគារ រង្គសាល និង ភោជនីយដ្ឋានឈ្មោះ សណ្ឋាគារច័ន្ទរះ ចុះថ្ងៃទី ៣០-៧-៩៤ ។ ហត្ថលេខារបស់ឈ្មោះ ស៊ុន គីមសុង នៅលើលិខិតទាំងពីរខាងលើនេះ គឺភាគីលោក នេត វណ្ណៈ បានទទួលស្គាល់ថា ជាហត្ថលេខារបស់ឈ្មោះ ស៊ុន គីមសុង ពិតប្រាកដ ។ ក្រោយពីនាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រក្រសួងមហាផ្ទៃ បានធ្វើកោសល្យវិច្ច័យហើយ បានសន្និដ្ឋានថា : ស្នាមហត្ថលេខារបស់ឈ្មោះ ស៊ុន គីមសុង ចុះនៅប័ណ្ណប្រគល់ប្រាក់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៤ និង កិច្ចសន្យាជួលសណ្ឋាគារ រង្គសាល និង ភោជនីយដ្ឋានឈ្មោះ សណ្ឋាគារច័ន្ទរះ គឺ មិនមែនជាហត្ថលេខា ចុះដោយឈ្មោះ ស៊ុន គីមសុង តែម្នាក់ទេ ។ សូមក្រុមប្រឹក្សាជំនុំជំរះ ពិចារណាទៅមើល បើហត្ថលេខារបស់ឈ្មោះ ស៊ុន គីមសុង ចុះនៅលើលិខិតទាំងពីរខាងលើ ត្រូវបានធ្វើកោសល្យវិច្ច័យទៅឃើញថា មិនមែនចុះដោយ ស៊ុន គីមសុង តែម្នាក់ទេ ដូច្នេះតើនរណាជាអ្នកក្លែងហត្ថលេខានេះដែរ តើស៊ុន គីមសុង ខ្លួនឯងជាអ្នកក្លែង ឬ ឈ្មោះ នេត វណ្ណៈ ជាអ្នកក្លែង ឬមួយក៏លោក នូ សុវណ្ណារ៉ា ជាអ្នកក្លែងទៀត ។

ចំណុចមួយទៀតគឺ នៅតុលាការក្រុងក្ដី សាលាឧទ្ធរណ៍ក្ដី ពុំបានធ្វើកោសល្យវិច្ច័យលើហត្ថលេខារបស់ ស៊ុន គីមសុង នៅក្នុងលិខិតទាំងពីរខាងលើនេះទេ ទោះជាមានដីកាចាត់តាំង អ្នកជំនាញចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៥ ក៏ដោយ គឺគេធ្វើតែហត្ថលេខារបស់ ស៊ុន គីមសុង នៅក្នុងកិច្ចសន្យាជួលសណ្ឋាគាររង្គសាលភោជនីយដ្ឋានឈ្មោះ សណ្ឋាគារច័ន្ទរះ ចុះថ្ងៃទី ៣០-៧-៩៤ ជាមួយហត្ថលេខានៅក្នុងកិច្ចសន្យាអាជីវកម្មទ្វេរភាគី ចុះថ្ងៃទី ០៥-៨-៩៤ ប៉ុណ្ណោះ ដើម្បីទំលាក់កំហុសមកលើលោក នូ សុវណ្ណារ៉ា ។

ចំនុចទាំងពីរខាងលើនេះហើយ ដែលនាងខ្ញុំលើកយកមកជាភស្តុតាងថ្មីសំរាប់ប្តឹងសើរើ ។

- លោក ហែម វុន មេធាវីការពារម្ចាស់បណ្តឹងសើរើបានសន្និដ្ឋាននាពេលសវនាការថា :

នៅក្នុងរឿងក្តីនេះ វាមានទំនាក់ទំនងរវាងកិច្ចសន្យា៣ : ទីមួយ កិច្ចសន្យាចុះថ្ងៃទី ២៨-០៧-៩៤ , ទីពីរ កិច្ចសន្យា ចុះថ្ងៃទី ៣០-៧-៩៤ និង ទីបី កិច្ចសន្យាទ្វេរភាគី ចុះថ្ងៃទី ០៥-៨-៩៤ ប៉ុន្តែ ចំណាត់ការរបស់តុលាការថ្នាក់ក្រោមកន្លងមក បានលើកយកតែកិច្ចសន្យាពីរប៉ុណ្ណោះ មកធ្វើជាសំអាងហេតុ ក្នុងការវិនិច្ឆ័យសេចក្តីគឺ កិច្ចសន្យា ចុះថ្ងៃទី ៣០-៧-៩៤ និង កិច្ចសន្យាអាជីវកម្មទ្វេរភាគី ចុះថ្ងៃទី ០៥-៨ ៩៤ ។ ការចាត់ការរបស់តុលាការថ្នាក់ក្រោមគឺ វាខុសនឹងគតិច្បាប់ទាំងស្រុង ព្រោះលើកយកកិច្ចសន្យា ដែលភាគី ដើមចោទបដិសេធចោលឈប់ប្រើប្រាស់មកចាត់ការ។ តាមកំណត់ហេតុប្រជុំចុះថ្ងៃទី ០៥-៨-៩៤ ដែលចុះហត្ថលេខា ដោយភាគីម្ចាស់សណ្ឋាគារមានលោក នេត វណ្ណៈ , ស៊ុន គឹមសុង , វ៉ុត ដារ៉ុច និង គង់ សុផល មានខ្លឹមសារថា ភាគីទាំងពីរយល់ព្រមបដិសេធឈប់ប្រើប្រាស់កិច្ចសន្យា ចុះថ្ងៃទី ៣០-៧-៩៤។

ក្រុមប្រឹក្សាជំនុំជំរះជាទីគោរព ភស្តុតាងថ្មីដែលខ្ញុំបាទលើកយកមកប្តឹងសើរើនេះគឺ :

ទី១ : ដីកាចាត់តាំងអ្នកជំនាញលេខ ៣០៧៨ តព្រ ចុះថ្ងៃទី ២១-៧-៩៥ របស់តុលាការក្រុងភ្នំពេញ បានសំរេចចាត់តាំងឱ្យ ការិយាល័យនគរបាលបច្ចេកទេសក្រុងភ្នំពេញ ធ្វើកោសល្យវិច្ច័យ លើប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ និង កិច្ចសន្យាជួលសណ្ឋាគាររង្គសាល និង ភោជនីយដ្ឋានឈ្មោះ សណ្ឋាគារច័ន្ទរះ ចុះថ្ងៃទី ៣០-៧-៩៤ ដែលចុះហត្ថលេខា ដោយឈ្មោះ ស៊ុន គឹមសុង តើជាហត្ថលេខារបស់ឈ្មោះ ស៊ុន គឹមសុង តែម្នាក់ឬទេ ។ ហត្ថលេខារបស់ ស៊ុន គឹមសុង នៅក្នុងកិច្ចសន្យាខាងលើនេះ ហើយដែលភាគីលោក នេត វណ្ណៈ បានទទួលស្គាល់ថា ជាហត្ថលេខារបស់ ស៊ុន គឹមសុង ប្រាកដមែន ។ ប៉ុន្តែលទ្ធផលកោសល្យវិច្ច័យខាងលើនេះ នៅក្នុងសំណុំរឿងគ្មានទេ បានសេចក្តីថា គេពុំធ្វើកោសល្យវិច្ច័យ ដើម្បីងាយស្រួលក្នុងការទំលាក់កំហុសមកលើលោក នូ សុវណ្ណារ៉ា ។

ក្រុមប្រឹក្សាជំនុំជំរះ ជាទីគោរព ខ្ញុំបានជឿជាក់ថា បើកោសល្យវិច្ច័យ ខាងលើ ត្រូវបានគេធ្វើហើយនោះ ហើយដាក់នៅក្នុងសំណុំរឿង នោះតុលាការប្រាកដជាមានមូលដ្ឋាន ច្បាស់លាស់សំរាប់ធ្វើការប្រៀបធៀបរវាងហត្ថលេខារបស់ឈ្មោះ ស៊ុន គឹមសុង នៅក្នុងកិច្ចសន្យាទាំងបី ជាក់ជាមិនខាន ។

ទី២ : យោងតាមប្រកាសលទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ២៧-០២-២០០១ របស់នាយកដ្ឋាននគរបាលបច្ចេកទេស វិទ្យាសាស្ត្រក្រសួងមហាផ្ទៃ នៅលើហត្ថលេខារបស់ឈ្មោះ ស៊ុន គឹមសុង នៅក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ ជាមួយហត្ថលេខារបស់ ស៊ុន គឹមសុង នៅក្នុងកិច្ចសន្យាជួលសណ្ឋាគាររង្គសាល និង ភោជនីយដ្ឋានឈ្មោះសណ្ឋាគារច័ន្ទរះ ចុះថ្ងៃទី ៣០-៧-៩៤ បានបញ្ជាក់យ៉ាងច្បាស់ថា : ស្នាមហត្ថលេខារបស់ឈ្មោះស៊ុន គឹមសុង ចុះនៅប័ណ្ណប្រគល់ប្រាក់ ថ្ងៃទី ៣០-៧-៩៤ និង កិច្ចសន្យាជួលសណ្ឋាគាររង្គសាល និង ភោជនីយដ្ឋានឈ្មោះ សណ្ឋាគារច័ន្ទរះ គឺមិនមែនជាហត្ថលេខា ចុះដោយឈ្មោះ ស៊ុន គឹមសុង តែម្នាក់ទេ ។ ដូច្នេះយោងតាមលទ្ធផលកោសល្យវិច្ច័យខាងលើផ្ទុះបញ្ជាំងឱ្យឃើញថា ឈ្មោះ ស៊ុន គឹមសុង តែម្នាក់ឯង ចុះហត្ថលេខា ពីរដង គឺខុសគ្នាទាំងពីរលើក ហេតុនេះខ្ញុំបាទ សន្និដ្ឋានថា ហត្ថលេខារបស់ឈ្មោះ

ស៊ុន គឹមសុង នៅក្នុងប័ណ្ណប្រគល់ប្រាក់ ចុះថ្ងៃទី ៣០-៧-៩៤ និង ហត្ថលេខារបស់ ស៊ុន គឹមសុង នៅក្នុងកិច្ចសន្យាជួលសណ្ឋាគារវង្គសាល និង ភោជនីយដ្ឋានឈ្មោះ សណ្ឋាគារច័ន្ទរះ ចុះថ្ងៃទី ៣០-៧-៩៤ និង ហត្ថលេខារបស់ឈ្មោះ ស៊ុន គឹមសុង នៅក្នុងកិច្ចសន្យាអាជីវកម្មទ្វេរភាគី ចុះថ្ងៃទី ០៥-៨-៩៤ គឺពិតជាហត្ថលេខារបស់ឈ្មោះ ស៊ុន គឹមសុង តែម្នាក់គត់ ហើយលោក នូ សុវណ្ណារ៉ា ពុំបានក្លែងហត្ថលេខារបស់ឈ្មោះ ស៊ុន គឹមសុង ដូចការចោទប្រកាន់របស់តុលាការកន្លងមកនោះទេ ។

ចំណុចខាងលើនេះហើយ ដែលខ្ញុំបាទ លើកជាសំអាងហេតុថ្មីសំរាប់ធ្វើការប្តឹងសើរើនេះ ។ អាស្រ័យហេតុនេះ ខ្ញុំបាទសូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាទទួលបណ្តឹងសើរើរបស់កូនក្តីខ្ញុំបាទ ដោយយោងតាមមាត្រា ២៣០ ចំណុចទី៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- តំណាងមហាអយ្យការ អម តុលាការកំពូល បានសន្និដ្ឋានបន្ថែមថា សូមតុលាការពិនិត្យពិចារណាតាមច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់ម្ចាស់បណ្តឹងសើរើ និង សេចក្តីសន្និដ្ឋានរបស់មេធាវី ម្ចាស់បណ្តឹងសើរើ .
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសើរើ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ របស់អ្នកស្រី សរ ភិនសុគន្ធី ប្រពន្ធទណ្ឌិត នូ សុវណ្ណារ៉ា បានប្តឹងពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០ របស់តុលាការកំពូល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ វុមក្រុមសើរើបានតាមមាត្រា ២២៧ និង ២៣២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា លទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ការិយាល័យកោសល្យវិច្ច័យក្រសួងមហាផ្ទៃ ដែលអ្នកស្រី សរ ភិនសុគន្ធី លើកឡើងថា ជាភស្តុតាងដើម្បីប្តឹងសុំសើរើពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី ១២-៧-២០០០ របស់តុលាការកំពូល និងថា ទណ្ឌិត នូ សុវណ្ណារ៉ា ជាប្តីរបស់អ្នកស្រី ជាមនុស្សសុច្ចរិតនោះ តុលាការកំពូល ពុំអាចទទួលបានឡើយ ពីព្រោះតាមសាលដីកាព្រហ្មទណ្ឌខាងលើ ទណ្ឌិត នូ សុវណ្ណារ៉ា ត្រូវបានចោទប្រកាន់ពីបទក្លែងហត្ថលេខាលើលិខិតកិច្ចសន្យា ចុះថ្ងៃទី ០៥-៨-៩៤ ។ ប៉ុន្តែលទ្ធផលកោសល្យវិច្ច័យថ្មី ពុំបានបញ្ជាក់ថា លោក ស៊ុន គឹមសុង បានយល់ព្រមជួលសណ្ឋាគារ ឬ ចុះហត្ថលេខា លើកិច្ចសន្យាជួលសណ្ឋាគារឱ្យឈ្មោះ នូ សុវណ្ណារ៉ា ដែលជាភស្តុតាង ដោះបន្ទុកឱ្យទណ្ឌិតរួចខ្លួន ពីការផ្តន្ទាទោសតាមមាត្រា ២៣០ នៃច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌឡើយ ។ ពីព្រោះលោក ស៊ុន គឹមសុង ព្រមទាំងសាក្សីទាំងអស់បានបញ្ជាក់ថា លោក ស៊ុន គឹមសុង ពុំបានចុះកិច្ចសន្យានោះទេ ហើយចម្លើយទាំងនេះ ក៏ស្របគ្នា និង

លទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ០៩-១០-៩៥ និង ចុះថ្ងៃទី ១២-៦-៩៦ ដែលបញ្ជាក់ថា ហត្ថលេខាលើកិច្ចសន្យាចុះថ្ងៃទី ០៥-៨-៩៤ ជាហត្ថលេខាក្លែងក្លាយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខម្ចាស់បណ្តឹងសើរើ

១- លើកបណ្តឹងសុំសើរើ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ របស់អ្នកស្រី សរ ភិនសុគន្ធី ដែលប្តឹងសុំសើរើ ពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី ១២-៧-២០០០ របស់តុលាការកំពូល ចោលជាអសារបង់ ។

២- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០១ ។